NATIONAL BOWEL CANCER SCREENING PROGRAM

Australian Government

<Date> លេខអត្តសញ្ញាណ: <Consumer ID>

<Participant Given Name> < Participant Family Name >
<Preferred Mailing Address>
<Preferred Mailing Address >
<LOCALITY> <STATE> <POSTCODE>

ជូនចំពោះ <Participant Given Name> < Participant Family Name >

ខ្ញុំសូមអញ្ជើញលោកអ្នកឲ្យចូលរួមនៅក្នុងកម្មវិធីជាតិលើការពិនិត្យរកមើលជម្ងឺមហារីកពោះវៀន។ គ្រឿងប្រដាប់សំរាប់ធ្វើតេស្ត ជាមួយនិងសេចក្តីណែនាំព្រមទាំងកូនសៀវភៅព័ត៌មានគឺមានដាក់ផ្ញើមកជាមួយនិងលិខិតនេះ។ សូមចំណាយពេលដើម្បីអានព័ត៌មាននេះ។ ការធ្វើតេស្តគឺឥតគិតថ្លៃទេ ការធ្វើតេស្តនឹងចំណាយពេលត្រឹមតែ២-៣នាទីប៉ុណ្ណោះ ចំនួនពីរលើកខុសៗគ្នា។

កូនសៀវភៅព័ត៌មានផ្តល់នូវព័ត៌មានបន្ថែមអំពីការធ្វើតេស្ត។ ដើម្បីចូលរួម លោកអ្នកត្រូវប្រមូលយកសំណាកលាមកពីរលើក ដោយធ្វើតាមសេចក្តីណែនាំដូចមានចុះនៅក្នុងគ្រឿងប្រដាប់។ លោកអ្នកគួរតែ:

- រក្សាទុកគ្រឿងប្រដាប់នៅក្នុងកន្លែងត្រជាក់ ទាំងមុន និងក្រោយពេលដែលលោកអ្នកបានប្រមូលសំណាក។
- បំពេញការធ្វើតេស្ត**ឲ្យបានយ៉ាងឆាប់បំផុត ដែលអាចធ្វើទៅបាន**;
- បំពេញហ្វ៍ម**ព័ត៌មានលំអិតអំពីអ្នកចូលរួម**; ហើយ
- ផ្ញើសំណាកទាំងពីររបស់លោកអ្នក ជាមួយហ្វ៍មព័ត៌មានលំអិតអំពីអ្នកចូលរួម ទៅមន្ទីរពិសោធន៍ផ្នែករោគសាស្ត្រ ដោយប្រើស្រោមសំបុត្រឆ្លើយតបដែលបានបង់ថ្លៃតែមរួច មាននៅក្នុងគ្រឿងប្រដាប់។

មន្ទីរពិសោធន៍ផ្នែករោគសាស្ត្រនឹងធ្វើវិភាគលើសំណាកនេះ ហើយប្រសិនបើគេរកឃើញឈាម (នេះត្រូវស្គាល់ថាលទ្ធផលវិជ្ជមាននៃការធ្វើតេស្ត) លោកអ្នកនឹងត្រូវគេស្នើសុំឲ្យទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក ដើម្បីពិគ្រោះអំពីលទ្ធផលនោះ។ **លទ្ធផលវិជ្ជមានពុំមានន័យថាលោកអ្នកមានជម្ងឺមហារីកពោះវៀនទេ**។ វាត្រឹមតែមានន័យថាឈាមត្រូវបានរកឃើញនៅក្នុងលាមករបស់លោកអ្នក ហើយលោកអ្នកគួរជួបវេជ្ជបណ្ឌិតលោកអ្នកដើម្បីធ្វើតេស្តបន្ថែម ក្នុងការរកឲ្យឃើញនូវដើមហេតុនៃការចេញឈាម។ មនុស្សភាគច្រើនដែលមានលទ្ធផលតេស្តវិជ្ជមានពុំកើតជម្ងឺមហារីកទេ។

ជម្ងឺមហារីកពោះវៀន ប្រសិនបើមាននោះ អាចបង្ហាញឲ្យឃើញនូវរោគសញ្ញាយ៉ាងតិចតួចពីដំបូង។ ដោយហេតុនេះហើយបានជាការធ្វើតេស្តនេះគឺសំខាន់ជាខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើលោកអ្នកឃើញមានរោគសញ្ញាណាមួយដូចមានចុះនៅក្នុងកូនសៀវភៅព័ត៌មាននេះ លោកអ្នកគួរទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក។ ក៏ដូចគ្នានេះដែរ ប្រសិនបើលោកអ្នកមានប្រវត្តិគ្រួសារដែលកើតជម្ងឺមហារីកពោះវៀនដ៏ធ្ងន់ធ្ងរ លោកអ្នកក៏គួរនិយាយជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន។

ខ្ញុំសង្ឃឹមថាលោកអ្នកនឹងជ្រើសរើសចូលរួមនៅក្នុងកម្មវិធីដ៏សំខាន់នេះ។ ប្រសិនបើលោកអ្នកពុំចង់ចូលរួមទេ សូមបំពេញហ្វ៍ម Opt-Off/ Suspend (មិនចូលរួម/ផ្អាកមិនចូលរួម) នៅផ្នែកខាងក្រោយនៃកូនសៀវភៅព័ត៌មាន។ ប្រសិនបើលោកអ្នកមានសំនួរណាមួយអំពីគ្រឿងប្រដាប់ធ្វើតេស្ត ឬកម្មវិធី សូមទូរស័ព្ទមកខ្សែទូរស័ព្ទផ្តល់ព័ត៌មានលេខ **1800 118 868** ក្នុងអម្លុងពេលម៉ោងធ្វើការ ឬនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់លោកអ្នក។

ដោយនូវសេចក្តីគោរព

សាស្ត្រាចារ្យ **John Horvath AO**
នាយកបុគ្គលិកផ្នែកវេជ្ជសាស្ត្រ

NBCSR C001